# គណបក្សសង្គ្រោះជាតិ
# CAMBODIA NATIONAL RESCUE PARTY

សង្គ្រោះ បម្រើ ការពារ

លេខ.០៥៤/១៦...គ.ស.ជ.

## សេចក្ដីសម្រេច
## សន្និបាតក្រុមប្រឹក្សាជាតិលើកទី២
## ថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៦

- បានឃើញលក្ខន្តិកៈរបស់គណបក្សសង្គ្រោះជាតិ
- បានឃើញបទបញ្ជាផ្ទៃក្នុងរបស់គណបក្សសង្គ្រោះជាតិ
- យោងសេចក្ដីសម្រេចរបស់គណៈកម្មាធិការនាយក ថ្ងៃទី០៦ ខែមីនា ឆ្នាំ២០១៦

**គណបក្សសង្គ្រោះជាតិ** បានប្រារព្ធសន្និបាតក្រុមប្រឹក្សាជាតិលើកទី២ ថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៦ ចាប់ពីម៉ោង ៨ព្រឹក ដល់ម៉ោង ៣រសៀល នៅរាជធានីភ្នំពេញ ដែលមានសមាជិក សមាជិកាក្រុមប្រឹក្សាជាតិរបស់គណបក្សសង្គ្រោះជាតិទូទាំងប្រទេស តំណាងចលនានានា និងសាខាគណបក្សក្រៅប្រទេស ចូលរួមប្រមាណ ១៥០០នាក់។

អង្គសន្និបាត ប្រព្រឹត្តទៅក្រោមអធិបតីភាព ៖

- លោក **សម រង្ស៊ី** ប្រធានគណបក្ស
- លោក **កឹម សុខា** អនុប្រធានគណបក្ស

ក្រោយពីបានស្ដាប់ ការពិភាក្សា និងអនុម័ត នូវរបាយការណ៍ស្ដីពីសកម្មភាពរយៈពេលពីរឆ្នាំកន្លងមក និងសេចក្ដីថ្លែងការណ៍ ស្ដីពី ការកំណត់ទិសដៅ និងគោលនយោបាយ សម្រាប់អនុវត្តរយៈពេលពីរឆ្នាំខាងមុខ (២០១៦-២០១៨) អង្គសន្និបាតបានអនុម័តនូវសេចក្ដីសម្រេចដូចខាងក្រោម៖

### សម្រេច

១. គាំទ្រ នូវរបាយការណ៍សកម្មភាពរបស់គណបក្សសង្គ្រោះជាតិ ដែលបានអនុវត្តរយៈពេលពីរឆ្នាំកន្លងមក (២០១៤-២០១៦)។

២. គាំទ្រ នូវសុន្ទរកថាបើកសន្និបាតក្រុមប្រឹក្សាជាតិលើកទី២ របស់ លោកប្រធាន **សម រង្ស៊ី** និងលោកអនុប្រធាន **កឹម សុខា** ដែលបានចង្អុលបង្ហាញនូវទិដ្ឋភាពនយោបាយរួម ក៏ដូចជា ចក្ខុវិស័យសម្រាប់គណបក្សសង្គ្រោះជាតិផងដែរ។

ទីស្នាក់ការកណ្ដាល : ផ្ទះលេខ ៥៧៦ ផ្លូវជាតិលេខ ២ សង្កាត់ចាក់អង្រែលើ ខណ្ឌមានជ័យ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
Headquarters : House #576, National Road N°2, Sangkat Chakangres Leu, Khan Mean Chey, Phnom Penh, Kingdom of Cambodia
Tel : 012 90 57 75 / Email: cnrpcabinet@gmail.com

៣. គាំទ្រ នូវគោលដៅជាយុទ្ធសាស្ត្ររបស់គណបក្សសង្គ្រោះជាតិ ដែលបានកំណត់ និងអនុវត្ត គឺ **ធ្វើដំណើរឆ្ពោះទៅរកការបោះឆ្នោត ដើម្បីនាំមកនូវការផ្លាស់ប្តូរ**។ ផ្លាស់ប្តូរដោយសន្តិវិធី ផ្លាស់ប្តូរជាវិជ្ជមាន។

៤. គាំទ្រ នូវគោលការណ៍ និងគោលជំហរនយោបាយដែលគណបក្សសង្គ្រោះជាតិបានប្រកាន់យក គឺ អហិង្សា មិនគុំកួន សងសឹក មិនយកខ្មែរណាជាសត្រូវ ខ្មែរតែមួយ ជាពិសេស គោលជំហររឹងមាំ តែមិនរឹងរូស ទន់ភ្លន់តែមិនទន់ជ្រាយ។

៥. គាំទ្រ នូវការដឹកនាំដ៏ត្រឹមត្រូវរបស់លោកប្រធាន **សម រង្ស៊ី** និងលោកអនុប្រធាន **កឹម សុខា** ក្នុងការដឹកនាំគណបក្សសង្គ្រោះជាតិកន្លងមក ហើយនឹងគាំទ្រលោកទាំងពីររួមគ្នាបន្តដឹកនាំគណបក្សសង្គ្រោះជាតិបន្តទៅមុខទៀត ដើម្បីធ្វើដំណើរឆ្ពោះទៅរកជោគជ័យតាមសេចក្តីប្រាថ្នារបស់ប្រជាពលរដ្ឋខ្មែរ គឺការផ្លាស់ប្តូរដោយសន្តិវិធី និងជាវិជ្ជមាន។

៦. គាំទ្រ និងលើកទឹកចិត្ត ឲ្យថ្នាក់ដឹកនាំគណបក្សសង្គ្រោះជាតិបន្តការតស៊ូ ព្យាយាម អត់ធ្មត់ គឺ **មិនឈ្លោះ មិនឆ្លើយ មិនឆ្លង** ដើម្បីដោះស្រាយបញ្ហាដោយសន្តិវិធី តាមរយៈការជួបចរចាគ្នាជាមួយភាគីពាក់ព័ន្ធ ជាពិសេសជាមួយថ្នាក់ដឹកនាំគណបក្សកាន់អំណាច តាមគោលការណ៍នៃ **វប្បធម៌សន្ទនា** ទោះបីជា វប្បធម៌សន្ទនាកន្លងមកនេះ មានភាពរអាក់រអួល មិនទាន់បានដោះស្រាយបញ្ហាដែលនៅ សេសសល់ជាផ្លែផ្កាហើយក៏ដោយ។

៧. គណបក្សសង្គ្រោះជាតិ ត្រូវតែប្រើប្រាស់យន្តការរបស់ខ្លួនដែលមានស្រាប់ ឲ្យដំណើរការយ៉ាងសកម្មរស់រវើក ដើម្បីបម្រើជាតិ និងប្រជាពលរដ្ឋខ្មែរ ស្របតាមគោលនយោបាយរបស់គណបក្ស ទាំងយន្តការផ្ទៃក្នុងគណបក្ស ទាំងយន្តការក្នុងក្របខណ្ឌរដ្ឋ ជាពិសេស សមាជិកសភា គណៈកម្មការនានាក្នុងសភា សមាជិកក្រុមប្រឹក្សារាជធានី-ខេត្ត ក្រុង-ស្រុក-ខណ្ឌ និងឃុំ-សង្កាត់ ជាដើម។

៨. គាំទ្រ នូវការបង្កើតក្រុមសមាជិកសភាគណបក្សសង្គ្រោះជាតិ និងវិធានផ្ទៃក្នុងក្រុមសមាជិកសភាគណបក្សសង្គ្រោះជាតិ ធ្វើឲ្យសមាជិកសភាយើងបំពេញការងារឲ្យមានប្រសិទ្ធភាព ស្របតាមគោលនយោបាយរបស់គណបក្ស ដើម្បីបម្រើការពារផលប្រយោជន៍ជាតិ និងផលប្រយោជន៍ប្រជាពលរដ្ឋខ្មែរ។

៩. គណបក្សសង្គ្រោះជាតិ ត្រូវរៀបចំ និងផ្តល់ឱកាសឲ្យរឹតតែទូលំទូលាយថែមទៀត ជូនប្រជាពលរដ្ឋខ្មែរទាំងក្នុង និងក្រៅប្រទេសមកពីមជ្ឈដ្ឋាននានា បញ្ញវន្ត សង្គមស៊ីវិល អង្គការក្រៅរដ្ឋាភិបាល អ្នកជំនាញ ជនជាតិភាគតិច ខ្មែរឥស្លាម ជនជាតិដើម អ្នកស្នេហាជាតិមកពីគណបក្សនយោបាយនានា ជាពិសេសរៀបចំបណ្តុះបណ្តាល និងផ្តល់ឱកាសឲ្យស្ត្រី និងយុវជនចូលរួមក្នុងនយោបាយគណបក្សសង្គ្រោះជាតិយ៉ាងសកម្ម និងឈានទៅបន្តវេនដឹកនាំឲ្យបានកាន់តែច្រើនឡើង។

១០. ថ្លែងអំណរគុណ និងកោតសរសើរចំពោះប្រជាពលរដ្ឋខ្មែរទាំងក្នុង និងក្រៅប្រទេស ដែលបានគាំទ្រ និងបន្តគាំទ្រ គោលនយោបាយរបស់គណបក្សសង្គ្រោះជាតិ ជាពិសេស ដែលបានលើកទឹកចិត្តមកលើថ្នាក់ដឹកនាំគ្រប់លំដាប់ថ្នាក់។

១១. ថ្លែងអំណរគុណចំពោះសហគមន៍អន្តរជាតិ ដែលបានតាមដាននូវស្ថានភាពនយោបាយនៅកម្ពុជាយ៉ាងយកចិត្តទុក និងបានសម្តែងអំពីកង្វល់របស់ខ្លួនជុំវិញការរំលោភសិទ្ធិមនុស្ស ការបំពានលើគោលការណ៍ប្រជាធិបតេយ្យ បំពានទៅលើប្រជាពលរដ្ឋទន់ខ្សោយ ការចាប់ខ្លួនឃុំខ្លួន អ្នកដឹកនាំសកម្មជនគណបក្សសង្គ្រោះជាតិ ការប្រើអំពើហិង្សាលើអ្នកតំណាងរាស្ត្រជាដើម។

១២. គណបក្សសង្គ្រោះជាតិ ត្រូវប្រមូលផ្តុំនូវសក្តានុពលរបស់ខ្លួន ផ្តោតលើការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់នាឆ្នាំ២០១៧ខាងមុខនេះ ក្នុងគោលបំណងចាក់គ្រឹះនៃលទ្ធិប្រជាធិបតេយ្យឲ្យរឹងមាំ និងធ្វើវិមជ្ឈការអំណាច វិមជ្ឈការធនធានមនុស្ស វិមជ្ឈការថវិកា នយោបាយ សេដ្ឋកិច្ច សង្គមកិច្ច និងសេវាសាធារណៈនានា ដល់មូលដ្ឋានឃុំ-សង្កាត់ ស្របតាមកម្មវិធីនយោបាយមូលដ្ឋានរបស់គណបក្សសង្គ្រោះជាតិ ដែលបានប្រមែប្រមូលនូវបញ្ហា និងសំណូមពររបស់ប្រជាពលរដ្ឋដែលបានស្រង់មតិពីមូលដ្ឋានភូមិ ឃុំ កន្លងមក ហើយបានរៀបចំក្រងរួចហើយនោះ។

ធ្វើនៅ ថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៦

**ប្រធានគណបក្ស**

គណបក្ស សង្គ្រោះជាតិ
CAMBODIA NATIONAL RESCUE PARTY

**សម រង្ស៊ី**